## ឧបសម្ព័ន្ធទី ១៖ ការវិភាគផ្នែកច្បាប់លើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ក្នុងខែកក្កដា ឆ្នាំ២០១៧

ឧបសម្ព័ន្ធនេះវិភាគលើបទប្បញ្ញត្តិសំខាន់ៗមួយចំនួននៃសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ("ច្បាប់គណបក្សនយោបាយ") ដែលត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។ ការវិភាគនេះគឺផ្អែកទៅលើរដ្ឋធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិទាក់ទិននឹងសិទ្ធិមនុស្សដែលចងកាតព្វកិច្ចដល់កម្ពុជា។ បទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធមានលើកឡើងនៅក្នុងឧបសម្ព័ន្ធទី២។

### *មាត្រា ៦-ថ្មី (ពីរ)[1]៖*

*គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយដូចខាងក្រោម៖*

*១- ធ្វើឲ្យមានអបគមន៍ ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី។*

*២- ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ។*

*៣- ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ។*

*៤- បង្កើតកងកម្លាំងប្រដាប់អាវុធ។*

*៥- ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ។*

***៦- ប្រើប្រាស់សារជាសម្លេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សរបស់ខ្លួន។***

***៧- យល់ព្រមដោយចំហ ឬដោយតុណ្ហីភាព ឬឃុបឃិតជាមួយទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ឲ្យធ្វើសកម្មភាពណាមួយដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។***

***៨- គាំទ្រ ឬរៀបចំផែនការ ឬឃុបឃិតជាមួយរាល់បុគ្គលដែលធ្វើសកម្មភាពក្នុងគោលបំណងប្រឆាំងនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ដូចមានចែងពីចំណុចទី១ ដល់ចំណុចទី៥ ខាងលើ។***

### យោបល់លើមាត្រា ៦ នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖

ការធ្វើវិសោធនកម្មមាត្រា ៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ កាលពីលើកទី១ (កថាខណ្ឌទី១ ដល់ទី៥) ដែលត្រូវបានអនុម័តក្នុងខែមីនា ឆ្នាំ២០១៧ បានទទួលការរិះគន់ជាច្រើនចំពោះខ្លឹមសារមិនច្បាស់លាស់ និងស្រពេចស្រពិលនៃមាត្រាទាំងនោះ។[2] កថាខណ្ឌទី១ ដល់ទី៥ ដែលហាមឃាត់សកម្មភាពមួយចំនួន ដែលអាចនាំឲ្យអន្តរាយដល់ "ឯកភាពជាតិ" និង "សន្តិសុខនៃរដ្ឋ" ហាក់ដូចជាបើកទូលាយ

[1] សេចក្តីស្នើច្បាប់វិសោធនកម្មគឺត្រូវបានសរសេរដោយមានបន្ថែមពណ៌ឲ្យខ្មៅ។

[2] សម្រាប់ការវិភាគទាំងមូលជុំវិញច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយកាលពីខែមីនា ឆ្នាំ២០១៧ សូមចូលទៅ៖ ឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា "ការវិភាគលើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ" (ថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៧ < http://bit.ly/2nxRx8M >

ឲ្យមានការបកស្រាយបែបអត្តនោម័តិ និងបែបនយោបាយ ដោយសារតែលក្ខណៈស្រពេចស្រពិលនៃពាក្យទាំងនេះ។

ជាជាងការយកឱកាសដើម្បីកែតម្រូវចន្លោះប្រហោងទាំងនេះ ការធ្វើវិសោធនកម្មថ្មីបន្ថែមលើមាត្រា ៦ (កថាខណ្ឌទី៦ ដល់ទី៨) ពង្រីកវិសាលភាពនៃបទប្បញ្ញត្តិទាំងនោះកាន់តែខ្លាំងឡើង និងធ្វើការរឹតត្បិតដោយពុំសមហេតុផលបន្ថែមទៅលើសេរីភាពខាងសមាគម និងការបញ្ចេញមតិ។ តាមមាត្រា ៦ នៃសេចក្តីស្នើច្បាប់វិសោធនកម្មនេះ ការបំពានចំណុចណាមួយនៃមាត្រានេះអាចឲ្យក្រសួងមហាផ្ទៃផ្អាកសកម្មភាព (ដោយពុំមានថិរវេលាកំណត់ជាក់លាក់) របស់គណបក្សនយោបាយណាមួយបានតាមមាត្រា ៣៨ ថ្មី និងអាចឈានដល់ការរំលាយគណបក្សនោះតាមមាត្រា ៤៤ ថ្មី (ពីរ)។

កថាខណ្ឌទី៦ ដល់ទី៨ នៃសេចក្តីស្នើច្បាប់វិសោធនកម្មថ្មីនេះត្រូវបានវិភាគដូចខាងក្រោម។

***ការវិភាគមាត្រា ៦- ថ្មី (ពីរ) (កថាខណ្ឌទី៦) នៃសេចក្តីស្នើច្បាប់វិសោធនកម្មៈ***

- បញ្ញត្តិនេះអាចហាមប្រាមគណបក្សនយោបាយក្នុងការប្រើប្រាស់ "សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាព" របស់ទណ្ឌិតដើម្បីកេងចំណេញផ្នែកនយោបាយ ឬផលប្រយោជន៍នយោបាយរបស់គណបក្សខ្លួន។
- បញ្ញត្តិនេះមានខ្លឹមសារមិនច្បាស់លាស់ដែលពុំអាចទទួលយកបាន ដែលជាការរំលោភបំពានទៅលើគោលការណ៍នៃភាពច្បាស់លាស់ផ្នែកច្បាប់ ដែលតម្រូវថា ច្បាប់ត្រូវតែច្បាស់ និងអាចព្យាករណ៍បាន ដែលអាចឲ្យបុគ្គលទាំងឡាយយល់បានក្នុងករណីដែលពួកគេប្រឈមទៅនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬផ្នែករដ្ឋបាល។ ឧទាហរណ៍ ដូចជាមិនច្បាស់ថាពាក្យ "ប្រើប្រាស់" ឬ "សកម្មភាព" ចង់សម្តៅយ៉ាងដូចម្តេចឲ្យប្រាកដ។
- ម្យ៉ាងទៀត បញ្ញត្តិនេះមានអត្ថន័យទូលំទូលាយពេក ដែលធ្វើការហាមប្រាមដោយពុំសមហេតុផលទៅលើសកម្មភាពនានា។ ការហាមប្រាមនេះបង្កឲ្យមានការរឹតត្បិតដោយពុំសមាមាត្រ ហើយហេតុដូច្នេះនឹង បង្កើតបានជាការរឹតត្បិតដោយពុំសមហេតុផលទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគមរបស់គណបក្សនយោបាយនានា និងសមាជិករបស់ពួកគេ។
- ខណៈសិទ្ធិមនុស្សខ្លះអាចត្រូវបានរឹតត្បិតដោយស្របច្បាប់បាន ការរឹតត្បិតណាមួយអាចធ្វើបានតែក្នុងកាលៈទេសៈដែលមានការកំណត់យ៉ាងចង្អៀត និងជាក់លាក់តែប៉ុណ្ណោះ ដូចដែលមានអធិប្បាយលម្អិតនៅក្នុងឧបសម្ព័ន្ធទី២។ លក្ខខណ្ឌទាំងនេះមិនត្រូវបានបង្ហាញនៅក្នុងករណីនេះនោះទេ។ ជាពិសេស ការហាមប្រាមទៅលើការប្រើប្រាស់ "សំឡេង រូបភាព និងឯកសារ ឬសកម្មភាព" របស់ទណ្ឌិត ពុំអាចចាត់ទុកថាជា "ការចាំបាច់" ក្នុងការសម្រេចគោលបំណងគ្រប់គ្រងគណបក្សនយោបាយដែលមានចែងនៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយឡើយ។

- បញ្ញត្តិនេះក៏អាចបង្កើតបានជាបន្ទុកបន្ថែមទៀតដែលត្រូវចំណាយលើការរៀបចំ និងផ្នែកហិរញ្ញវត្ថុ ដែលពុំសមាមាត្រដល់គណបក្សនយោបាយ ដែលមិនបានអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ នៅពេលដែលច្បាប់នេះត្រូវបានអនុម័ត។ សូមពិនិត្យ '*យោបល់លើមាត្រា ៤៨ នៃសេចក្តីស្នើច្បាប់វិសោធនកម្ម*' ខាងក្រោមសម្រាប់ការវិភាគបន្ថែម។

***ការវិភាគលើមាត្រា ៦- ថ្មី (ពីរ) (កថាខណ្ឌទី៧) នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖***

- បញ្ញត្តិនេះអាចហាមប្រាមគណបក្សនយោបាយក្នុងការ "យល់ព្រមដោយចំហ ឬដោយតុណ្ហីភាព ឬក៏ឃុបឃិតជាមួយទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ក្នុងការធ្វើសកម្មភាពណាមួយដើម្បីកេងចំណេញ/ផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន"។
- បញ្ញត្តិនេះនឹងនាំឲ្យមានការរឹតត្បិតដោយពុំសមហេតុផលយ៉ាងទូលំទូលាយ និងជាអចិន្ត្រៃយ៍ទៅលើសិទ្ធិរបស់ទណ្ឌិតក្នុងការចូលរួមកិច្ចការសាធារណៈ (ដូចដែលមានធានាក្នុងមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។ បញ្ញត្តិនេះក៏អាចរឹតត្បិតមិនត្រឹមត្រូវទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគមរបស់ទណ្ឌិតទាំងនោះផងដែរ (មាត្រា ១៩ និងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។ ទោះបីជាបញ្ញត្តិនេះ និងទណ្ឌកម្មដែលពាក់ព័ន្ធនឹងមាត្រានេះ (ក្រោមមាត្រា ៣៨-ថ្មី និងមាត្រា ៤៤-ថ្មី) ផ្តោតលើគណបក្សនយោបាយ ជាជាងបុគ្គលក្តី តែផលប៉ះពាល់ជាក់ស្តែងនៃមាត្រានេះនឹងធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់បុគ្គល តាមរយៈការដាក់ទណ្ឌកម្មទៅលើគណបក្សនយោបាយដែលបុគ្គលទាំងនោះមានការគាំទ្រ។
- យោងតាមសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ[3] សូម្បីតែទណ្ឌិតដែលកំពុងអនុវត្តទោសក៏ "ត្រូវទទួលបានសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" [...] "លើកលែងតែកម្រិតទាំងនោះត្រូវបានបង្ហាញពីភាពចាំបាច់ដោយហេតុថាត្រូវស្ថិតនៅក្នុងពន្ធនាគារ"។ ការបដិសេធទាំងស្រុងចំពោះសិទ្ធិរបស់ទណ្ឌិតក្នុងការបញ្ចេញមតិផ្នែកនយោបាយ និងការចូលរួមក្នុងវិស័យនយោបាយនឹងបង្កើតបានជាការរឹតត្បិតយ៉ាងខ្លាំងនូវសិទ្ធិមនុស្សរបស់ពួកគេ ហើយហេតុដូច្នេះ អាចនឹងត្រូវធ្វើឡើងដោយផ្អែកលើ "ភាពចាំបាច់" ក្នុងការសម្រេចគោលបំណងត្រឹមត្រូវតាមច្បាប់ និងត្រូវមានការអនុវត្តយ៉ាងសមាមាត្រដូចដែលមានអធិប្បាយលម្អិតនៅក្នុងឧបសម្ព័ន្ធទី២។ ការហាមឃាត់ចំពោះទណ្ឌិតបែបនេះចំពោះសកម្មភាពនយោបាយដូចជាមិនអាចចាត់ទុកបានថាជាវិធានការរឹតត្បិតតិចតួចក្នុងការ

[3] ឧត្តមស្នងការសិទ្ធិមនុស្ស, "គោលការណ៍មូលដ្ឋានសម្រាប់ការប្រព្រឹត្តចំពោះអ្នកទោស", សេចក្តីសម្រេចរបស់មហាសន្និបាត លេខ៤៥/១១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០ < http://bit.ly/1bDgrVi >

សម្រេចគោលបំណងដើម្បីចង់គ្រប់គ្រងគណបក្សនយោបាយដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីគណបក្សនយោបាយនោះទេ។

- ដូច្នេះ ច្បាប់ ឬលិខិតបទដ្ឋានទាំងឡាយណាដែលរារាំងទណ្ឌិតទាំងអស់ រួមទាំងអ្នកដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ មិនឲ្យបង្ហាញការគាំទ្រសម្រាប់គណបក្សនយោបាយណាមួយ ឬមិនឲ្យចូលរួមក្នុងជីវភាពសាធារណៈ បង្កឲ្យមានការរឹតត្បិតដែលមិនអាចអនុញ្ញាតទៅបានចំពោះសិទ្ធិរបស់បុគ្គល តាមមាត្រា ១៩ មាត្រា ២២ និងមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមាត្រា ៣១ មាត្រា ៤១ មាត្រា ៤២ និងមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញ។
- លើសពីនេះទៀត ការហាមប្រាមលើការ "ព្រមព្រៀងដោយតុណ្ហីភាព" គឺពិតជាចំណុចដែលគួរឲ្យព្រួយបារម្ភខ្លាំង ដោយសារតែចំណុចនេះអាចឲ្យមានការបកស្រាយជាតុផ្សំចេតនាណាមួយតាមបែបអត្តនោម័តិចំពោះការមិនអើពើធ្វើសកម្មភាពរបស់គណបក្សនយោបាយ។ ការខកខានក្នុងការថ្កោលទោសចំពោះសកម្មភាពទាំងឡាយណារបស់ទណ្ឌិតអាចឲ្យគេយល់ថាជា "ការព្រមព្រៀងដោយតុណ្ហីភាព" និងប្រឈមនឹងការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។ ម្យ៉ាងទៀត ចំណុចនេះទំនងជាអាចបង្កើតហានិភ័យដែលថា គណបក្សនយោបាយមួយអាចប្រឈមនឹងទណ្ឌកម្មតាមរយៈការមិនអើពើធ្វើសកម្មភាព ដោយពុំចាំបាច់មានលក្ខខណ្ឌតម្រូវដែលថាថ្នាក់ដឹកនាំគណបក្សបានដឹងអំពីហេតុការណ៍នោះដែលបានបង្កើតឲ្យមានការទទួលខុសត្រូវ។
- ឧទាហរណ៍ គណបក្សនយោបាយអាចប្រឈមនឹងទណ្ឌកម្ម រួមទាំងការផ្អាកសកម្មភាព និងការរំលាយ ដោយសារខកខានក្នុងការបដិសេធនូវការគាំទ្រពីទណ្ឌិតណាម្នាក់ បើទោះជាថ្នាក់ដឹកនាំគណបក្សនោះពុំបានដឹងអំពីការគាំទ្រ និងពុំមានចេតនាយល់ស្របជាមួយនឹងសេចក្តីថ្លែងការណ៍ណាមួយនោះក្តី។ ក្នុងស្ថានភាពបែបនេះ កាលៈទេសៈដែលអាចឈានដល់ការដាក់ទណ្ឌកម្មលើគណបក្ស អាចស្ថិតនៅក្រៅវិសាលភាពនៃការគ្រប់គ្រងរបស់គណបក្សទាំងស្រុង។ ដោយហេតុថា មានទណ្ឌិតជាច្រើនពាន់នាក់នៅកម្ពុជា ហើយការបង្កើតកាតព្វកិច្ចបែបវិជ្ជមានឲ្យដល់គណបក្សនយោបាយក្នុងការថ្កោលទោសសេចក្តីថ្លែងការណ៍នានារបស់បុគ្គល ដែលទំនងជាមិនអាចតាមដានដឹងនៅក្នុងការអនុវត្តជាក់ស្តែង ការតម្រូវឲ្យអនុវត្តពេញលេញតាមមាត្រានេះពិតជាមិនអាចទៅរួចទេ និងអាចធ្វើឲ្យគណបក្សនយោបាយត្រូវប្រឈមនឹងហានិភ័យជាអចិន្ត្រៃយ៍។ ដោយសារតែមានផលលំបាកជាក់ស្តែងទាក់ទងនឹងការធានានូវការប្រតិបត្តិតាមការកំណត់បែបនេះ បញ្ញត្តិនេះពុំស៊ីសង្វាក់ជាមួយនឹងសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈតាមមាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

**ការវិភាគមាត្រា ៦- ថ្មី (ពីរ) (កថាខណ្ឌទី៨) នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖**

- បញ្ញត្តិនេះនឹងហាមប្រាមលើគណបក្សនយោបាយពីការ "គាំទ្រ ឬរៀបចំផែនការ ឬឃុបឃិតជាមួយបុគ្គលណាដែលធ្វើសកម្មភាពក្នុងគោលបំណងប្រឆាំងនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ដូចមានចែងពីចំណុចទី ១ ដល់ចំណុចទី ៥"។
- បញ្ញត្តិនេះនឹងពង្រីកវិសាលភាពយ៉ាងធំធេងនៃមាត្រា ៦ និងកាន់តែធ្វើឲ្យស្ថានភាពបែបទូលំទូលាយ និងមិនច្បាស់លាស់កាន់តែធ្ងន់ធ្ងរថែមទៀត។ ប្រការនេះក៏ទំនងដែលថាបញ្ញត្តិនេះអាចអនុវត្ត សូម្បីតែប្រសិនបើបុគ្គលនោះពុំមែនជាសមាជិករបស់គណបក្សនយោបាយណាមួយក៏ដោយ ហេតុដូច្នេះហើយ មិនស្ថិតនៅក្រោមវិសាលភាពនៃការហាមឃាត់នៅក្នុងចំណុចពីទី ១ ដល់ទី ៥ ឬប្រសិនបើ "ផែនការ" នោះមិនពាក់ព័ន្ធទាល់តែសោះទៅនឹងសកម្មភាពដែលបានហាមឃាត់នៅក្នុងចំណុចពីទី ១ ដល់ទី ៥។
- ដោយសារតែការកំណត់អំពី "ឯកភាពជាតិ" បែបស្រពេចស្រពិល និងមិនច្បាស់លាស់ដែលចែងនៅចំណុចទី ៥ ស្រាប់ទៅហើយនោះ ការពង្រីកការអនុវត្តមាត្រា ៦ គឺពិតជាគួរឲ្យព្រួយបារម្ភណាស់ ព្រោះចំណុចនេះនឹងពន្លាតវិសាលភាពសម្រាប់ការអនុវត្តតាមអំពើចិត្ត និង/ឬដែលផ្តោតលើគោលដៅណាមួយដោយផ្អែកលើមូលដ្ឋានបែបអត្តនោម័តិ ឬមានចរិតលក្ខណៈនយោបាយ។

*មាត្រា ១១-ថ្មី៖*

*គ្រប់គណបក្សនយោបាយត្រូវមានឈ្មោះ និងសញ្ញាសម្គាល់តាមការកំណត់ដូចខាងក្រោម៖*

*១. ឈ្មោះជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយ ត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយនានា។*

*២. ឈ្មោះរបស់គណបក្សនយោបាយ មិនត្រូវធ្វើឡើងដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចនៅលើឈ្មោះគណបក្សនយោបាយនានា ឬយកឈ្មោះរូបវន្តបុគ្គលមកដាក់ឡើយ។*

*៣. សញ្ញាសម្គាល់របស់គណបក្សនយោបាយមិនត្រូវចម្លង ឬយកតាមសញ្ញាជាតិ រូបភាព តំណាងឲ្យសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយល័ក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ឬរូបភាពរបស់រូបវន្តបុគ្គលឡើយ។*

**យោបល់លើមាត្រា ១១ នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖**

- មាត្រា ១១ កំណត់អំពីការជ្រើសរើសឈ្មោះ និងសញ្ញាសម្គាល់ ដែលគណបក្សនយោបាយអាចយកមកប្រើប្រាស់។ ចំណុចមួយចំនួននៃបទប្បញ្ញត្តិនេះបង្ហាញពីការរឹតត្បិតដែលអាចអនុញ្ញាតទៅបានលើសេរីភាពខាងការបញ្ចេញមតិ ខណៈដែលបទប្បញ្ញត្តិមួយចំនួនទៀតបង្កើតបានជាការជ្រៀតជ្រែកហួសហេតុទៅលើសកម្មភាពនានារបស់គណបក្សនយោបាយ ហេតុដូច្នេះហើយ មិនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិឡើយ ដូចបានរៀបរាប់ក្នុងឧបសម្ព័ន្ធទី២។

- ខណៈដែលជារឿងធម្មតា ឬមានហេតុផលសម្រាប់រដ្ឋក្នុងការគ្រប់គ្រងឈ្មោះ និងសញ្ញាសម្គាល់ដែលសម្រេចជ្រើសរើសដោយគណបក្សនយោបាយ ក្របខ័ណ្ឌនៃការគ្រប់គ្រងត្រូវតែគោរពសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគម។

*ការវិភាគលើមាត្រា ១១ (កថាខណ្ឌទី១) នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖*

- បញ្ញត្តិនេះចែងថា "ឈ្មោះជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយ ត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយនានា"។
- បញ្ញត្តិនេះផ្តល់ជាការរឹតត្បិតមួយដែលសមហេតុផល និងមានសម្អាងហេតុត្រឹមត្រូវទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគមដោយពិចារណាលើមាត្រា ១៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយសារតែមានផលប្រយោជន៍សាធារណៈពិតប្រាកដក្នុងការរក្សាភាពច្បាស់លាស់ជុំវិញអត្តសញ្ញាណរបស់គណបក្សនយោបាយ ហើយការរឹតត្បិតនេះសមាមាត្រទៅនឹងគោលបំណងនោះ។

*ការវិភាគលើមាត្រា ១១ (កថាខណ្ឌទី២) នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖*

- បញ្ញត្តិនេះចែងថា "ឈ្មោះរបស់គណបក្សនយោបាយ មិនត្រូវធ្វើឡើងដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចនៅលើឈ្មោះគណបក្សនយោបាយនានា ឬយកឈ្មោះរូបវន្តបុគ្គលមកដាក់ឡើយ"។
- ជាថ្មីម្តងទៀត ការហាមឃាត់លើ "ការសម្រួលបន្តិចបន្តួច" ផ្តល់នូវការរឹតត្បិតដែលសមហេតុផល និងមានសម្អាងហេតុត្រឹមត្រូវលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគម ដោយសារតែមានផលប្រយោជន៍សាធារណៈពិតប្រាកដក្នុងការរក្សាភាពច្បាស់លាស់ជុំវិញអត្តសញ្ញាណរបស់គណបក្សនយោបាយ ហើយការរឹតត្បិតនេះសមាមាត្រទៅនឹងគោលបំណងនោះ។ តែទោះជាយ៉ាងនេះក្តី ការរឹតត្បិតលើការប្រើប្រាស់ឈ្មោះរបស់រូបវន្តបុគ្គលគឺមានបញ្ហាដូចដែលបានពិភាក្សានៅក្នុងបរិបទនៃមាត្រា ១១ (កថាខណ្ឌទី៣) ខាងក្រោម។

*ការវិភាគលើមាត្រា ១១ (កថាខណ្ឌទី៣) នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖*

- បញ្ញត្តិនេះចែងថា "សញ្ញាសម្គាល់របស់គណបក្សនយោបាយមិនត្រូវចម្លង ឬយកតាមសញ្ញាជាតិ រូបភាពតំណាងឲ្យសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយល័ក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ឬរូបភាពរបស់រូបវន្តបុគ្គលឡើយ"។
- ការហាមឃាត់ការប្រើប្រាស់សញ្ញា និងរូបភាពជាតិបង្កើតបានជាការរឹតត្បិតតិចតួចទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ គោលបំណងនៃការរឹតត្បិតនេះគឺមិនច្បាស់លាស់ ហេតុដូច្នេះហើយ មិនអាចត្រូវបានចាត់ទុកថាបំពេញតាមលក្ខណវិនិច្ឆ័យដែលមានចែងនៅក្នុងមាត្រា ១៩ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

- ទោះជាយ៉ាងណាក្តី ការហាមឃាត់លើការប្រើប្រាស់ "រូបភាពរបស់រូបវន្តបុគ្គល" បង្កើតបានជាការហាមឃាត់ហួសហេតុ និងមិនសមហេតុផលទៅលើសេរីភាពខាងការបញ្ចេញមតិ។ ការហាមឃាត់រូបភាពទាំងអស់របស់គ្រប់បុគ្គលសម្រាប់ធ្វើជាសញ្ញាសម្គាល់គណបក្សនយោបាយមិនបម្រើឲ្យគោលបំណងត្រឹមត្រូវ ដូចជាសុខភាពសាធារណៈ ឬសន្តិសុខជាតិ ដូចដែលមានចែងនៅក្នុងមាត្រា ១៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះទេ។ ហេតុដូច្នេះហើយ បញ្ញត្តិនេះអាចនឹងបង្កើតបានជាការរឹតត្បិតមិនស្របតាមច្បាប់ទៅលើសេរីភាពខាងការបញ្ចេញមតិ។

*មាត្រា ៤៥ ថ្មី (ស្ទួន)៖*

*គណបក្សនយោបាយដែលបានសម្រេចផ្អាកសកម្មភាព មិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ។*

*ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលគណបក្សនយោបាយនោះត្រូវបានសម្រេចផ្អាកសកម្មភាព ឬត្រូវបានសម្រេចរំលាយ ស្របតាមច្បាប់នេះ។*

**យោបល់លើមាត្រា ៤៥ ថ្មី នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖**

- បញ្ញត្តិនេះអាចនឹងធ្វើឲ្យពុំមានលក្ខណៈសមាមាត្រ និងភាពធ្ងន់ធ្ងរនៃទណ្ឌកម្មដែលបានចែងនៅក្នុងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលបានអនុម័តពីមុនកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀត ដោយចែងថា គណបក្សនយោបាយដែលត្រូវបានផ្អាកសកម្មភាពអាចនឹងត្រូវហាមឃាត់ពីការចូលរួមប្រកួតប្រជែងការបោះឆ្នោត ដោយសារតែការបំពានច្បាប់ដែលមានលក្ខណៈមិនច្បាស់លាស់ និងដែលមិនអនុញ្ញាតឲ្យមានការហាមឃាត់បែបនេះបាន។ ការផ្អាកសកម្មភាពអាចធ្វើទៅបានក្នុងរយៈពេលមិនកំណត់ជាក់លាក់ ដោយតាមមាត្រា ៣៨ ថ្មី ដោយពុំចាំបាច់មានការត្រួតពិនិត្យតាមផ្លូវតុលាការ។ ការធ្វើឲ្យករណីនេះកាន់តែធ្ងន់ធ្ងរទៀតនោះគឺថា ច្បាប់ស្តីពីគណបក្សនយោបាយហាក់ដូចជាពុំមានចែងពីយន្តការសម្រាប់ឲ្យគណបក្សនយោបាយអាចប្តឹងជំទាស់នឹងការសម្រេចផ្អាកសកម្មភាព និងការហាមឃាត់ក្នុងការចូលរួមប្រកួតប្រជែងបោះឆ្នោត។
- ការហាមឃាត់គណបក្សនយោបាយពីការឈរឈ្មោះឲ្យគេបោះឆ្នោតរារាំងចំពោះការអនុវត្តគោលបំណងចម្បងរបស់គណបក្ស ព្រមទាំងជាការរារាំងសិទ្ធិក្នុងការចូលរួមតាមបែបប្រជាធិបតេយ្យរបស់សមាជិក បេក្ខជន និងអ្នកគាំទ្រ។ ចំណុចនេះបង្កើតបានជាការរឹតត្បិតយ៉ាងខ្លាំងលើសេរីភាពខាងសមាគម និងសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ ដែលអាចមានការរឹតត្បិតទៅបានតែក្នុងកាលៈទេសៈពិសេសជាក់លាក់តែប៉ុណ្ណោះ ហើយកាលៈទេសៈទាំងនោះមិនត្រូវបានបង្ហាញនៅក្នុងករណីនេះទេ។ ទណ្ឌកម្មដែលមានលក្ខណៈមិនសមាមាត្របែបនេះគឺមិនស្របតាមគោលការណ៍ប្រជាធិបតេយ្យ និងសេរីពហុបក្ស ដែលប្រទេសកម្ពុជាត្រូវគោរព ដូច្នេះហើយ

ចំណុចនេះមិនស្របនឹងមាត្រា ១(១) និងមាត្រា ៥១ នៃរដ្ឋធម្មនុញ្ញ ក៏ដូចជាមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

- បញ្ញត្តិនេះក៏មិនស្របនឹងបទប្បញ្ញត្តិសំខាន់ៗនៃកិច្ចព្រមព្រៀងស្តីពីសន្តិភាពទីក្រុងប៉ារីសផងដែរ។ នៅក្នុងមាត្រា ៤ នៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា មានលក្ខខណ្ឌមួយដែលចែងយ៉ាងច្បាស់ថា "ទម្រង់បែបបទនៃការបោះឆ្នោត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសមរម្យ ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត"។ ទោះជាយ៉ាងនេះក្តី បញ្ញត្តិនេះអាចដកហូតនូវ "ឱកាសគ្រប់គ្រាន់ និងសមរម្យ" របស់គណបក្សនយោបាយក្នុងការចូលរួមប្រកួតប្រជែងការបោះឆ្នោតនាពេលអនាគត ដោយឈរលើបទប្បញ្ញត្តិដែលមិនស្របនឹងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

*មាត្រា ៤៨ ថ្មី (ស្ទួន)៖*

*ចំពោះគណបក្សនយោបាយណាដែលមានឈ្មោះ ឬសញ្ញាសម្គាល់របស់គណបក្សជាឈ្មោះ ឬរូបភាពរបស់រូបវន្តបុគ្គល ត្រូវធ្វើការផ្លាស់ប្តូរឈ្មោះ ឬសញ្ញាសម្គាល់ឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល៩០ (កៅសិប) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន។*

**យោបល់លើមាត្រា ៤៨ នៃសេចក្តីស្នើច្បាប់វិសោធនកម្ម៖**

- បញ្ញត្តិនេះអាចបង្កើតបានជាបន្ទុកបន្ថែមទៀតដែលត្រូវចំណាយលើការរៀបចំ និងផ្នែកហិរញ្ញវត្ថុដែលពុំសមាមាត្រដល់គណបក្សនយោបាយណា ដែលមិនស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះនៅពេលដែលច្បាប់នេះត្រូវអនុម័ត។ មិនច្បាស់ថាតើបញ្ញត្តិនេះចាំបាច់ត្រូវឲ្យមានការផ្លាស់ប្តូរ ឬដកចេញនូវការដាក់បង្ហាញសញ្ញាសម្គាល់/ស្លាកសញ្ញាផ្សេងៗដែលអាចបង្កជាបញ្ហា (ឧទាហរណ៍ សម្ភារៈ និងសញ្ញាដែលត្រូវបោះពុម្ពដាក់តាំងជាសាធារណៈ) ឬប្រសិនបើបញ្ញត្តិនេះគ្រាន់តែតម្រូវឲ្យមានការផ្លាស់ប្តូរលើសញ្ញាសម្គាល់/ស្លាកសញ្ញា 'ផ្លូវការ' តែប៉ុណ្ណោះ។
- កង្វះភាពច្បាស់លាស់នៅក្នុងច្បាប់គឺបង្កជាបញ្ហាច្រើន និងរំលោភបំពានដល់គោលការណ៍នៃភាពច្បាស់លាស់ផ្នែកច្បាប់។ លើសពីនេះទៀត ប្រសិនបើមានការបកស្រាយបញ្ញត្តិនេះដោយតម្រូវឲ្យធ្វើការផ្លាស់ប្តូរសញ្ញាសម្គាល់ដែលដាក់តាំងសាធារណៈទាំងអស់ជាដើម ប្រការនេះនឹងបង្កើតបានបន្ទុកផ្នែកហិរញ្ញវត្ថុមិនសមហេតុផលទៅលើគណបក្សនយោបាយ ហេតុដូច្នេះ ជាការរឹតត្បិតសិទ្ធិសេរីភាពខាងសមាគម។

## ឧបសម្ព័ន្ធទី២ ៖ ភាតព្វកិច្ចសិទ្ធិមនុស្សដែលពាក់ព័ន្ធ

ឧបសម្ព័ន្ធនេះគូសបញ្ជាក់ពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្សទាំងឡាយដែលអាចអនុវត្តទៅបាននៅកម្ពុជា សម្រាប់ការពិចារណាទៅលើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ("ច្បាប់គណបក្សនយោបាយ") ដែលត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧។

## រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

### មាត្រា១ កថាខណ្ឌទី ១៖

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រ ដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

### មាត្រា ៣១[1]៖

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។

### មាត្រា ៣៥៖

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ។

### មាត្រា ៤១៖

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ

---

[1] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧ ដោយផ្អែកតាមការបកស្រាយរបស់ក្រុមប្រឹក្សាត្រង់មាត្រា៣១ បានបញ្ជាក់ពីការអនុវត្តដោយផ្ទាល់នៃច្បាប់អន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ រួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្រោមច្បាប់ជាតិ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ។

របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់។

**មាត្រា ៤២៖**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។

**មាត្រា ៥១ - ថ្មី (វិសោធនកម្មនៅខែមីនា ឆ្នាំ១៩៩៩)[2]៖**

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។

## <u>កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន)</u>[3]

**មាត្រា ២(១)៖**

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។

---

[2] ក្នុងកិច្ចព្រមព្រៀងស្តីពីសន្តិភាពក្រុងប៉ារីស ប្រទេសកម្ពុជាបានប្តេជ្ញាអនុវត្តប្រព័ន្ធនយោបាយជាក់លាក់មួយ គឺប្រព័ន្ធនយោបាយតាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស។ ក្នុងឧបសម្ព័ន្ធទី ៥ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា "បណ្តាគោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា" មាត្រា៤ ចែងនូវគោលការណ៍មួយចំនួនដូចតទៅ៖ "រដ្ឋធម្មនុញ្ញត្រូវប្រកាសថា កម្ពុជានឹងអនុវត្តប្រព័ន្ធប្រជាធិបតេយ្យ សេរី ដោយឈរលើមូលដ្ឋានពហុបក្ស។ រដ្ឋធម្មនុញ្ញត្រូវកំណត់ឲ្យមានការបោះឆ្នោតដ៏ត្រឹមត្រូវ និងតាមកាលវេលា។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតសិទ្ធិសម្រាប់បោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត តាមរបៀបបោះឆ្នោតដោយសកល និងស្មើភាព។ រដ្ឋធម្មនុញ្ញត្រូវអនុញ្ញាតឲ្យមានការបោះឆ្នោតដោយសម្ងាត់ ដោយតម្រូវឲ្យទម្រង់បែបបទនៃការបោះឆ្នោត ត្រូវផ្តល់ឱកាសគ្រប់គ្រាន់ និងសមរម្យ ដើម្បីរៀបចំ និងចូលរួមក្នុងដំណើរការបោះឆ្នោត"។

[3] ប្រទេសកម្ពុជា គឺជារដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាបានផ្តល់សច្ចាប័នកតិកាសញ្ញានេះក្នុងឆ្នាំ១៩៩២។

មាត្រា ១៩៖

១. ជនគ្រប់រូបមានសិទ្ធិប្រកាន់យមមតិយោបល់ដោយគ្មានការជ្រៀតជ្រែក។

២. ជនគ្រប់រូបមានសិទ្ធិ សេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។

៣. ការប្រើប្រាស់ដែលចែងក្នុងកថាខណ្ឌនៃមាត្រានេះ តម្រូវឲ្យមានករណីកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរឹតត្បិតមួយចំនួន ដែលត្រូវកំណត់ជាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី៖

(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ។

(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬ សីលធម៌សាធារណៈ។

មាត្រា ២២៖

១. ជនគ្រប់រូបមានសិទ្ធិចូលរួមជាសមាគមដោយសេរីជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើតសហជីព និងសិទ្ធិចូលជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

២. ការប្រើប្រាស់សិទ្ធិនេះ អាចមានការរឹតត្បិតដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែលចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

មាត្រា ២៥៖

ដោយគ្មានការបែងចែក ដូចដែលបានចែងក្នុងមាត្រា ២ និងដោយគ្មានការរឹតត្បិត ដែលមិនសមហេតុផល ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិ និងមានឱកាស៖

(ក) រួមចំណែកក្នុងការដឹកនាំកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាង ដែលខ្លួនជ្រើសរើសដោយសេរី។

(ខ) បោះឆ្នោត និងឈរឈ្មោះបោះឆ្នោត នៅក្នុងការបោះឆ្នោតពិតប្រាកដ តាមកាលកំណត់ទៀងទាត់ ជាសកល ស្មើភាព និងដោយសម្ងាត់ ដែលធានាការបញ្ចេញមតិដោយសេរីពីឆន្ទៈអ្នកបោះឆ្នោត។

(គ) ចូលបម្រើមុខងារសាធារណៈក្នុងប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌទូទៅដោយសមភាព។

## ការរឹតត្បិតដែលអាចអនុញ្ញាតបានចំពោះសិទ្ធិមនុស្ស

តាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការរឹតត្បិតជាក់លាក់លើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគមអាចអនុញ្ញាតទៅបានតែក្នុងកាលៈទេសៈជាក់លាក់ប៉ុណ្ណោះ។

ទាក់ទិននឹងសេរីភាពខាងការបញ្ចេញមតិ ការរឹតត្បិតណាមួយត្រូវតែៈ

១. កំណត់នៅក្នុងច្បាប់ និង

២. មានភាពចាំបាច់ៈ

ក. ដើម្បីគោរពសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ ឬ

ខ. សម្រាប់ការពារសន្តិសុខជាតិ ឬ

គ. សម្រាប់ការពារសណ្តាប់ធ្នាប់សាធារណៈ ឬ

ឃ. សម្រាប់ការពារសុខភាពសាធារណៈ ឬ

ង. សម្រាប់ការពារសីលធម៌សាធារណៈ។

៣. មានភាពសមាមាត្រទៅនឹងគោលបំណងដែលចង់សម្រេច និង

៤. អនុវត្តសម្រាប់តែគោលបំណងទាំងឡាយដែលត្រូវបានរៀបរាប់ និង

ង. ទាក់ទងដោយផ្ទាល់ទៅនឹងតម្រូវការជាក់លាក់ដែលការរឹតត្បិតទាំងនោះត្រូវបានផ្អែកលើសម្អាងច្បាស់លាស់។[4]

ច្បាប់ដែលត្រូវចែងអំពីការរឹតត្បិតនានាលើសេរីភាពខាងការបញ្ចេញមតិត្រូវតែបង្កើតឡើងដោយមានភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីឲ្យបុគ្គលគ្រប់រូបអាចគ្រប់គ្រងសកម្មភាពភាពរបស់ខ្លួនបាន។[5] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានសម្រេចថា នៅក្នុងបរិបទនៃការពិភាក្សាផ្នែកនយោបាយ គុណតម្លៃដែលស្ថិតនៅលើសេរីភាពខាងការបញ្ចេញមតិដែលមិនអាចគ្រប់គ្រងបានគឺមានកម្រិត "ខ្ពស់ខ្លាំងណាស់"។[6]

ស្រដៀងគ្នានេះដែរ ការរឹតត្បិតណាមួយលើសេរីភាពខាងសមាគមត្រូវតែៈ

១. កំណត់នៅក្នុងច្បាប់ និង

---

[4] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, ការអត្ថាធិប្បាយទូទៅលេខ ៣៤ (មាត្រា ១៩), ឯកសាររបស់ អ.ស.ប CCPR/C/GC/34 ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌទី២២។ អាចស្វែងរកបាននៅទីនេះៈ <http://www2.ohchr.org/english/bodies/hrc/docs/gc34.pdf>

[5] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, ការអត្ថាធិប្បាយទូទៅលេខ ៣៤ (មាត្រា ១៩), ឯកសាររបស់ អ.ស.ប CCPR/C/GC/34 ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌទី២៥។ អាចស្វែងរកបាននៅទីនេះៈ <http://www2.ohchr.org/english/bodies/hrc/docs/gc34.pdf>

[6] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, ការអត្ថាធិប្បាយទូទៅលេខ ៣៤ (មាត្រា ១៩), ឯកសាររបស់ អ.ស.ប CCPR/C/GC/34 ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌទី៣៨។ អាចស្វែងរកបាននៅទីនេះៈ <http://www2.ohchr.org/english/bodies/hrc/docs/gc34.pdf>

២. មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដូចជា៖

ក. ដើម្បីផលប្រយោជន៍នៃសន្តិសុខជាតិ ឬ

ខ. ដើម្បីផលប្រយោជន៍នៃសុវត្ថិភាពសាធារណៈ ឬ

គ. ដើម្បីផលប្រយោជន៍នៃសណ្តាប់ធ្នាប់សាធារណៈ ឬ

ឃ. សម្រាប់ការពារសុខភាពសាធារណៈ ឬ

ង. សម្រាប់ការពារសីលធម៌សាធារណៈ ឬ

ច. សម្រាប់ការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

៣. មានភាពសមាមាត្រទៅនឹងគោលបំណងដែលចង់សម្រេច និង

៤. អនុវត្តសម្រាប់តែគោលបំណងទាំងឡាយដែលត្រូវបានរៀបរាប់ និង

ង. ទាក់ទងដោយផ្ទាល់ទៅនឹងតម្រូវការជាក់លាក់ដែលការរឹតត្បិតទាំងនោះត្រូវបានផ្អែកលើសម្អាងច្បាស់លាស់។

មាត្រា ១ នៃច្បាប់ស្តីពីគណបក្សនយោបាយចែងថា ច្បាប់នេះមានគោលបំណង "កំណត់បែបបទ និងលក្ខខណ្ឌនៃការបង្កើត ការចុះបញ្ជី និងការធ្វើសកម្មភាពរបស់គណបក្សនយោបាយក្នុងព្រះរាជាណាចក្រកម្ពុជា"។ ជាគោលការណ៍ ការកំណត់តាមបែបសត្យានុម័តិបែបនេះបង្កើតបានជាធាតុផ្សំមួយនៃគោលបំណងស្របច្បាប់ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ។ ហេតុដូច្នេះ ការវាយតម្លៃទៅលើភាពសមាមាត្រនៃការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងសមាគម ដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទី១ ត្រូវបានរកឃើញថាមិនស្របនឹងគោលបំណងនេះទេ។